00857690

F30/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 01 / 11 / 2012
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: លេខ ០០១/១៨ កក្កដា ២០០៧ អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

នៅចំពោះមុខ: ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Florence Ndepele MUMBA
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទ: ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២

ភាសា: ខ្មែរ/អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្តីសម្រេចធ្វើចំណាត់ថ្នាក់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ
ហៅ 'ឌុច'

**សហមេធាវីការពារក្តីជនជាប់ចោទ**
ការ សាវុត្ថ
កង ឫទ្ធារី

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញសេចក្ដីសម្រេចនេះ ដោយអនុលោមតាមមាត្រា ១២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មាន ទាក់ទងនឹងសំណុំរឿង ("សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទឯកសារ")។ អង្គជំនុំជម្រះតុលាការកំពូល ក្នុងនាមជាការិយាល័យតុលាការចុងក្រោយដែលបានទទួលសំណុំឯកសារនៃសំណុំរឿង ០០១ មានសមត្ថកិច្ចត្រួតពិនិត្យឡើងវិញ លើឯកសារទាំងអស់នៅក្នុងសំណុំរឿងក្នុងគោលបំណងធ្វើចំណាត់ប្រភេទឡើងវិញលើឯកសារទាំងនោះ។

1. នៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានស្នើសុំយោបល់នានាពីគ្រប់ភាគី និងអង្គភាពពាក់ព័ន្ធទាំងអស់នៃ អ.វ.ត.ក ទៅលើគោលការណ៍ណែនាំដែលបានស្នើឡើងសម្រាប់ធ្វើចំណាត់ប្រភេទឯកសារឡើងវិញចំពោះសំណុំឯកសារនៃសំណុំរឿង ០០១[1]។ ដោយ ពិចារណាទៅលើសំណើជាប់ពាក់ព័ន្ធផ្សេងៗ និងលទ្ធផលនៃការពិគ្រោះយោបល់ចាំបាច់នានា នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានចេញ "សេចក្ដីសម្រេចលើគោលការណ៍ណែនាំស្ដីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង" ("សេចក្ដីសម្រេចលើគោលការណ៍ណែនាំ")[2]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ឯកសារណាមួយ ឬផ្នែកមួយនៃឯកសារនេះ[3] នឹងមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញឡើយ ក្នុងករណីដែលសំអាងហេតុសម្រាប់ធ្វើចំណាត់ប្រភេទឯកសារពេលមុននៅមានសុពលភាព[4] និងក្នុងករណីដែលឯកសារនោះត្រូវបានការពារដោយច្បាប់កម្មសិទ្ធិបញ្ញា ឬក្នុងករណីដែលឯកសារនោះមានការយល់ព្រមដែលហាមឃាត់ការផ្សព្វផ្សាយ ប៉ុន្តែមិនមានការយល់ព្រមពីប្រភពឯកសារនោះទេ[5]។

2. ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា ត្រូវរក្សាជាឯកសារសម្ងាត់ចំពោះឯកសារនានា ឬផ្នែកណាមួយនៃឯកសារទាំងនោះដែលបច្ចុប្បន្នត្រូវបានធ្វើចំណាត់ថ្នាក់ថាជា 'ឯកសារសម្ងាត់' ក្នុងនោះ

[1] ឯកសារ F30, អនុស្សរណៈអន្តរការិយាល័យ កម្មវត្ថុ៖ ការពិនិត្យឡើងវិញនូវឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុតដែលស្ថិតនៅក្នុងសំណុំឯកសារនៃសំណុំរឿង ០០១ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២។

[2] ឯកសារ F30/2, សេចក្ដីសម្រេចលើគោលការណ៍ណែនាំស្ដីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២។

[3] សេចក្ដីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(ឃ) ("ប្រសិនបើឯកសារណាមួយមានផ្នែកណាមួយដែលគួរជាឯកសារសាធារណៈ ឬផ្នែកណាមួយនៃឯកសារដែលគួរត្រូវបានធ្វើចំណាត់ថ្នាក់ថាជាឯកសារសម្ងាត់ ឬសម្ងាត់បំផុតនោះ មាត្រា ៣.៣ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការធ្វើចំណាត់ប្រភេទ ត្រូវយកមកអនុវត្ត។

[4] សេចក្ដីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(ខ) –(គ)។

[5] សេចក្ដីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(ង) យោងទៅសេចក្ដីណែនាំអនុវត្តស្ដីពីការធ្វើចំណាត់ប្រភេទ មាត្រា ១២.៣។

រួមមាន ព័ត៌មានទំនាក់ទំនងលម្អិតរបស់ជនរងគ្រោះដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី កំណត់ហេតុនៃដំណើរការនីតិវិធីដែលបានធ្វើឡើងជាអសាធារណៈ និងឯកសារសម្ងាត់ដែលត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងផ្សេងទៀត លើកលែងតែក្នុងករណីដែលសំអាងហេតុត្រូវរក្សាការសម្ងាត់លែងមានសុពលភាពទៀត[6]។ បន្ថែមពីលើនេះទៀត ត្រូវរក្សាជាឯកសារសម្ងាត់បំផុតចំពោះឯកសារនានា ឬផ្នែកណាមួយនៃឯកសារទាំងនោះដែលបច្ចុប្បន្នត្រូវបានធ្វើចំណាត់ថ្នាក់ថាជា 'ឯកសារសម្ងាត់បំផុត' ក្នុងនោះរួមមាន សំណើសុំវិធានការការពារ និងឯកសារជាប់ពាក់ព័ន្ធ ឯកសារនិងព័ត៌មានដែលត្រូវមានវិធានការការពារ ព្រមទាំងព័ត៌មានដែលទាក់ទងនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ លើកលែងតែក្នុងករណីដែលសំអាងហេតុត្រូវរក្សាការសម្ងាត់លែងមានសុពលភាពទៀត[7]។ ឯកសារទាំងអស់ផ្សេងទៀតត្រូវធ្វើចំណាត់ឡើងវិញ[8] អាស្រ័យលើការកោសលុបចាំបាច់ណាមួយ[9]។

3. នៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យអង្គភាពបណ្ណសារធ្វើដំណើរការនិងជូនដំណឹងពីឯកសារទាំងអស់ដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញភ្លាមៗថាជា 'ឯកសារសាធារណៈ'[10]។ អាស្រ័យហេតុនេះ អង្គភាពបណ្ណសារ នៃ អ.វ.ត.ក បានធ្វើដំណើរការ និងជូនដំណឹងពីឯកសារទាំងអស់ដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញថាជា 'ឯកសារសាធារណៈ'[11]។ ឯកសារផ្សេងទៀតត្រូវបានកំណត់បង្ហាញនៅក្នុងដីកាបង្គាប់របស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល ដែលតម្រូវឱ្យធ្វើការកោសលុបមុនពេលធ្វើចំណាត់ថ្នាក់ឡើងវិញ[12]។ ដោយសារមានការកោសលុបលើឯកសារ[13] និងការកំណត់អត្តសញ្ញាណឯកសារមួយចំនួនបន្ថែមទៀតដែលអាចត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញដោយគ្មានការកោសលុប[14]នោះ ទើបឥឡូវនេះ ឯកសារទាំងនេះ ត្រូវបានរៀបចំរួចរាល់ដើម្បីធ្វើចំណាត់ថ្នាក់ឡើង

---

[6] សេចក្តីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(ខ)។

[7] សេចក្តីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(គ)។

[8] សេចក្តីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(ក)។

[9] សេចក្តីសម្រេចលើគោលការណ៍ណែនាំ កថាខណ្ឌ ៧(ឃ)។

[10] ឯកសារ F30/2 (សម្ងាត់បំផុត), ដីការបស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២ (ដីកាបង្គាប់របស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល) កថាខណ្ឌ ៣ ឧបសម្ព័ន្ធ។

[11] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ឯកសារទាំងអស់បែបនេះ ឥឡូវនេះមានកំណត់សម្គាល់ដោយត្រាប្រើប្រាស់ដោយអង្គភាពបណ្ណសារ ដាក់ថា "ត្រូវបានធ្វើចំណាត់ឡើងវិញជាឯកសារសាធារណៈ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១២"។ មើល ឧបសម្ព័ន្ធ ក។

[12] ដីកាបង្គាប់របស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៣ (៣)។

[13] មើលឧបសម្ព័ន្ធ ក។

[14] មើលឧបសម្ព័ន្ធ ខ។

វិញជា 'ឯកសារសាធារណៈ'។ ឯកសារសេសសល់ផ្សេងទៀត ដែលបច្ចុប្បន្នកំពុងត្រូវបានធ្វើការកោសលុបឱ្យបានត្រឹមត្រូវ[15] ឬត្រូវបានកំណត់ថាត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញនៅពេលអនាគតនោះ នឹងត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញយ៉ាងឆាប់រហ័ស។

4. អង្គជំនុំជម្រះតុលាការកំពូលពិចារណាយល់ឃើញថា វាក៏មានប្រយោជន៍ខាងតម្លាភាពផងដែរដែលត្រូវចេញផ្សាយនូវឧបសម្ព័ន្ធ[16]នៃឯកសារដែលត្រូវបានធ្វើចំណាត់ឡើងវិញរួចហើយ[17] ព្រមទាំងឯកសារដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញដោយសេចក្តីសម្រេចនេះ[18]។

## ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល សម្រេចៈ**

**បង្គាប់ថា** ឯកសារដែលបានកែតម្រូវដូចមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ក នៃសេចក្តីសម្រេចនេះ ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញថាជា 'ឯកសារសាធារណៈ' ហើយ

**បង្គាប់ថា** ឯកសារទាំងនេះដែលមានបង្ហាញក្នុងឧបសម្ព័ន្ធ ខ នៃសេចក្តីសម្រេចនេះ ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញថាជា 'ឯកសារសាធារណៈ'។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

[15] ទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា នៅពេលដែលឯកសារណាមួយជាភាសាណាមួយត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ នោះឯកសារនេះក្នុងភាសាមួយទៀតត្រូវមានចំណាត់ថ្នាក់ឯកសារដូចគ្នាតាមដីកាបង្គាប់។

[16] មើលឧបសម្ព័ន្ធ គ។

[17] ដីកាបង្គាប់របស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៤ (ពិចារណាថា បញ្ជីឯកសារទាំងអស់ដែលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញក្នុងអំឡុងពេលត្រួតពិនិត្យឡើងវិញលើសំណុំឯកសារនៃសំណុំរឿង ០០១) ។

[18] មើលឧបសម្ព័ន្ធ ក។